# ព្រះត្រៃឯក
# TRINITY

ព្រះទ្រង់មានព្រះវត្តមានជាបុគ្គលព្រះបីអង្គតាំងពីអស់កល្បជានិច្ចមកម្ល៉េះ៖ ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ហើយអង្គនីមួយៗ គឺជាព្រះមួយរយភាគរយ ហើយមានព្រះតែមួយគត់ប៉ុណ្ណោះ។

## ត្រៃសណ្ឋាននិយម (Modalism)

ការបង្រៀនខុសឆ្គង "ត្រៃសណ្ឋាននិយម" អះអាងថាមានអង្គតែមួយទេដែលបានលេចមកឲ្យយើងឃើញជាបីសណ្ឋាន ឬក៏បីបែប។

ឧទាហរណ៍មិនល្អ

ព្រះត្រៃឯកមានលក្ខណៈដូចជាទឹក ព្រោះទឹកអាចមានជា ទឹកកក ចំហាយទឹក ឬក៏ទឹក ហើយក៏នៅតែជាទឹកដដែល។

ទឹកមិនដែលមានសណ្ឋានបីក្នុងពេលតែមួយនោះទេ។ ប៉ុន្តែព្រះមិនដូច្នោះទេ អង្គនីមួយៗជាព្រះមួយរយភាគរយជានិច្ច ក្នុងពេលតែមួយ។

## មានព្រះតែមួយគត់ប៉ុណ្ណោះ

ចោទិយកថា ៦:៤
យ៉ូហាន ១៧:៣

បើអ្នកបដិសេធ នោះអ្នកខុសឆ្គងហើយ ដោយជឿលើត្រៃទេពនិយម (Tri-theism)




## ក្រោមបង្គាប់និយម (Subordinationism)

ការបង្រៀនខុសឆ្គង "ក្រោមបង្គាប់និយម" អះអាងថាព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធស្ថិតនៅក្រោមបង្គាប់របស់ព្រះវរបិតា ទាំងខាងផ្នែកលក្ខណៈ និងឋានៈ។

ឧទាហរណ៍មិនល្អ

ព្រះត្រៃឯកគឺប្រៀបដូចជាដួងអាទិត្យ ព្រោះដួងអាទិត្យមាន តួ ពន្លឺ និងកំដៅ ហើយទាំងអស់នេះជាដួងអាទិត្យ។

ពន្លឺ និងកំដៅជះសាយចេញមក ហើយក៏ស្ថិតនៅបានដោយសារតែមានតួ។ ប៉ុន្តែព្រះមិនដូច្នោះទេ អង្គទាំងបីមានភាពស្មើគ្នា ហើយគង់នៅតាំងពីអស់កល្បជានិច្ច។

## អង្គទាំងបីមានភាពស្មើគ្នា ហើយគង់នៅតាំងពីអស់កល្បជានិច្ច

យ៉ូហាន ១០:៣០
កិច្ចការ ៥:១-៤
២សាំយូអែល ២៣:២-៣
ហេព្រើរ ១:៣

បើអ្នកបដិសេធ នោះអ្នកខុសឆ្គងហើយ ដោយជឿលើក្រោមបង្គាប់និយម (Subordinationism)

## ត្រៃទេពនិយម (Tri-theism)

ការបង្រៀនខុសឆ្គង "ត្រៃទេពនិយម" បដិសេធពីការដែលមានព្រះតែមួយ ហើយអះអាងថាមានព្រះបីអង្គ

ឧទាហរណ៍មិនល្អ

ព្រះត្រៃឯកគឺប្រៀបដូចជាស៊ុត ព្រោះស៊ុតមានបីផ្នែក៖ ផ្នែកស ផ្នែកលឿង និងសំបក ប៉ុន្តែផ្នែកទាំងបីនេះគឺជាស៊ុតតែមួយ។

ផ្នែកនីមួយៗគឺគ្រាន់តែជាផ្នែកតែមួយប៉ុណ្ណោះ ហើយយើងមិនអាចហៅថាជាស៊ុតទាំងមូលបានទេ។ ប៉ុន្តែព្រះមិនដូច្នោះទេ អង្គនីមួយៗមានលក្ខណៈជាព្រះមួយរយភាគរយ។

## បុគ្គលព្រះមានបីអង្គ

លោកុប្បត្តិ ១:១-២
ម៉ាថាយ ២៨:១៩
លូកា ៣:២១-២២
យ៉ូហាន ១:១-៣; ១៤

បើអ្នកបដិសេធ នោះអ្នកខុសឆ្គងហើយ ដោយជឿលើត្រៃសណ្ឋាននិយម (Modalism)

ព្រះវរបិតាជាស្ថាបត្យករដ៏អស្ចារ្យក្នុងការបង្កើត ការសង្គ្រោះ និងការបង្ហើយ។ ហើយទ្រង់ជាអង្គដែលរៀបចំផែនការ ដឹកនាំ និងបញ្ជូន។ ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធស្ម័គ្រព្រះទ័យចុះចូលចំពោះព្រះវរបិតាខាងឯតួនាទី ទោះបីជាព្រះអង្គទាំងពីរមានភាពជាព្រះស្មើគ្នានឹងព្រះវរបិតាក៏ដោយ។

ព្រះរាជបុត្រាស្ដាប់បង្គាប់ព្រះវរបិតា សម្រេចផែនការសង្គ្រោះផងដែរ។ ហើយព្រះអង្គរួមគ្នាជាមួយនឹងព្រះវរបិតាក្នុងការចាត់ព្រះវិញ្ញាណបរិសុទ្ធមកបំពេញព្រះរាជកិច្ចដែលទ្រង់បានចាប់ផ្ដើម។ ព្រះអង្គថ្វាយសិរីល្អដល់ព្រះវរបិតាក្នុងគ្រប់កិច្ចការទាំងអស់ ។

ព្រះវិញ្ញាណបរិសុទ្ធបំពេញសម្រេចព្រះរាជកិច្ចដែលបានគ្រោងទុកដោយព្រះវរបិតា និងចាប់ផ្ដើមដោយព្រះរាជបុត្រា។ ព្រះវិញ្ញាណបរិសុទ្ធថ្វាយសិរីល្អដល់ព្រះរាជបុត្រាក្នុងគ្រប់កិច្ចការទាំងអស់។

VISUALTHEOLOGY.CHURCH
ផ្លូវពិត plovpit.com